**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ១៤១ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៣ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២៣១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន



៩

- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ន ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៣២៥ អនក្រ.បក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១០៤ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- បានឃើញអនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិដែលសរសេរជាអក្សរកាត់ថា **គ.ក.អ.** ដើម្បីទទួលបន្ទុកដឹកនាំនិងសម្របសម្រួលការអនុវត្តការងារកែទម្រង់នៅតាមក្រសួង ស្ថាប័ន ដែលរួមមាន ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការកែទម្រង់ច្បាប់ សំដៅលើកកម្ពស់អភិបាលកិច្ចក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងរដ្ឋលេខាធិការដ្ឋានលើកលែងក្រសួងការពារជាតិ។ ការបង្កើតគណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចនៅតាមស្ថាប័នផ្សេងទៀតចំណុះអង្គការនីតិប្រតិបត្តិ ត្រូវសម្រេចដោយស្ថាប័នសាមីផ្ទាល់ ផ្អែកលើយោបល់នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់។



9

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់ គ.ក.អ.

**មាត្រា៣ .-**

**គ.ក.អ.** ជាយន្តការរួមរបស់ក្រសួង ស្ថាប័ន ដែលមានតួនាទីដឹកនាំ គាំទ្រ សម្របសម្រួល ជំរុញ និងធានានូវការអនុវត្តការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចរបស់រាជរដ្ឋាភិបាលក្នុងក្រសួង ស្ថាប័ន ប្រកបដោយសង្គតិភាព សុខដុមនីយកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដើម្បីលើកកម្ពស់អភិបាលកិច្ចរបស់ក្រសួង ស្ថាប័នសាមី។

**មាត្រា៤ .-**

**គ.ក.អ.** មានភារកិច្ចដូចតទៅ៖

១- ដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាលប្រកបដោយសង្គតិភាពនិងសុខដុមនីយកម្មក្នុងក្រសួង ស្ថាប័ន។

២- សិក្សាស្រាវជ្រាវ វិភាគ និងដាក់ចេញនូវយុទ្ធសាស្ត្រដើម្បីលើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័ន។

៣- ពិនិត្យនិងធានាការផ្សារភ្ជាប់រវាងគោលបំណងនិងផែនការសកម្មភាពនៃការដ្ឋានកែទម្រង់របស់រាជរដ្ឋាភិបាល ជាមួយនឹងគោលនយោបាយនិងយុទ្ធសាស្ត្រនៅក្នុងវិស័យរបស់ក្រសួង ស្ថាប័ន ដើម្បីធានានូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រ។

៤- សម្របសម្រួលនិងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការជាតិនិងអន្តរជាតិ ពាក់ព័ន្ធនឹងការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចនិងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងវិស័យរបស់ក្រសួង ស្ថាប័ន។

៥- ធានានូវការផ្សារភ្ជាប់គ្នារវាងការអភិវឌ្ឍសមត្ថភាពមន្ត្រី ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងការលើកកម្ពស់គុណភាពការងារឆ្លើយតបនឹងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល។

៦- ជំរុញការកែទម្រង់និងបរិវត្តកម្មឌីជីថល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការងារក្នុងក្រសួង ស្ថាប័ន។

៧- ផ្តល់នូវធាតុចូលឬអនុសាសន៍ពាក់ព័ន្ធទៅនឹងបញ្ហាប្រឈមនិងគំនិតផ្តួចផ្តើមថ្មីៗ ដល់ការដ្ឋានកែទម្រង់នានារបស់រាជរដ្ឋាភិបាល ដើម្បីមានវិធានការគាំទ្រដល់ការលើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័ន។

៨- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័នសាមីនិងផ្តល់របាយការណ៍ទៀងទាត់តាមការកំណត់ ជូនគណៈកម្មាធិការកែទម្រង់ដែលមានការពាក់ព័ន្ធ។

## ជំពូកទី៣
## សមាសភាព គ.ក.អ.

**មាត្រា៥ .-**

**គ.ក.អ.** មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួង ស្ថាប័ន | ប្រធាន |
| - រដ្ឋលេខាធិការប្រចាំការ | អនុប្រធានអចិន្ត្រៃយ៍ |
| - ប្រធានក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ | អនុប្រធាន |



9

- ប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អនុប្រធាន
- ប្រធាន/អនុប្រធានគណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការនិង វិសហមជ្ឈការ អនុប្រធាន
- ប្រធានក្រុមការងារកែទម្រង់ច្បាប់ អនុប្រធាន
- រដ្ឋលេខាធិការ និង/ឬអនុរដ្ឋលេខាធិការ មួយចំនួន សមាជិក
- អគ្គនាយក ឬថ្នាក់ប្រហាក់ប្រហែល សមាជិក
- ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន សមាជិក
- អគ្គលេខាធិការក្រសួង ស្ថាប័ន លេខាធិការ។

សមាសភាពជាក់ស្តែងនៃ **គ.ក.អ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ក.អ.

**មាត្រា៦ .-**

ប្រធាន **គ.ក.អ.** អាចប្រគល់សិទ្ធជូនអនុប្រធានអចិន្ត្រៃយ៍ ឬអនុប្រធានណាម្នាក់ ដើម្បីដឹកនាំការងារប្រចាំថ្ងៃជំនួសបាន។

**មាត្រា៧ .-**

**គ.ក.អ.** ត្រូវប្រជុំយ៉ាងតិចរៀងរាល់៣(បី)ខែម្តងឬតាមការចាំបាច់ តាមការកោះអញ្ជើញរបស់ប្រធាន **គ.ក.អ.**។ ក្នុងករណីចាំបាច់ ប្រធាន **គ.ក.អ.** អាចប្រគល់សិទ្ធជូនអនុប្រធានណាម្នាក់ ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**មាត្រា៨ .-**

**គ.ក.អ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ អាជ្ញាធរ ដៃគូអភិវឌ្ឍ តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិល ទីប្រឹក្សាឬអ្នកជំនាញការជាតិនិងអន្តរជាតិ ចូលរួមប្រជុំពិគ្រោះយោបល់តាមការចាំបាច់។

**មាត្រា៩ .-**

**គ.ក.អ.** មានសិទ្ធប្រើត្រារបស់ក្រសួង ស្ថាប័នសាមី សម្រាប់កិច្ចដំណើរការរបស់ខ្លួន។

**មាត្រា១០ .-**

**គ.ក.អ.** មានលេខាធិការដ្ឋានមួយដើម្បីគាំទ្រដល់កិច្ចដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## លេខាធិការដ្ឋាននៃ គ.ក.អ.

**មាត្រា១១ .-**

អគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័នសាមី បំពេញមុខងារជាលេខាធិការដ្ឋាននៃ **គ.ក.អ.**។ រចនាសម្ព័ន្ធចំណុះអគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន ដែលមានស្រាប់ ត្រូវផ្តល់ការគាំទ្រក្នុងការអនុវត្តតួនាទីនិងភារកិច្ចរបស់ **គ.ក.អ.** ដូចមានកំណត់ក្នុងមាត្រា៤នៃអនុក្រឹត្យនេះ។

ការរៀបចំលេខាធិការដ្ឋាននៃ **គ.ក.អ.** របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ត្រូវកំណត់ដោយឡែក ផ្អែកលើយោបល់នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់។



9

**មាត្រា១២ .-**

ក្នុងក្របខ័ណ្ឌជាលេខាធិការដ្ឋាននៃ **គ.ក.អ.** អគ្គលេខាធិការដ្ឋានក្រសួង ស្ថាប័ន ត្រូវបំពេញភារកិច្ចដូចតទៅ៖

១- គាំទ្រនិងសម្របសម្រួលការងារ ដើម្បីធានាដំណើរការ ការបំពេញតួនាទីនិងភារកិច្ចរបស់ **គ.ក.អ.**។

២- គាំទ្រការសិក្សាស្រាវជ្រាវ វិភាគ និងស្នើនូវយុទ្ធសាស្ត្រលើការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័ន។

៣- សហការនិងសម្របសម្រួលជាមួយអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នសាមី ក្រសួង ស្ថាប័ននានា អង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍនិងអ្នកពាក់ព័ន្ធ ដើម្បីផ្តល់ការគាំទ្រនិងជំរុញការអនុវត្តការងារកែទម្រង់តាមការតម្រង់ទិសរបស់ **គ.ក.អ.**។

៤- សម្របសម្រួលការរៀបចំផែនការសកម្មភាពនិងថវិកា ព្រមទាំងការកំណត់សូចនាករសមិទ្ធកម្មជាក់លាក់ ដើម្បីធានាការអនុវត្តការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័ន។

៥- សម្របសម្រួលការរៀបចំ និងជំរុញការអនុវត្តផែនការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័នរបស់ក្រសួង ស្ថាប័ន ឆ្លើយតបនឹងគោលបំណងនិងយុទ្ធសាស្ត្រនៃការកែទម្រង់របស់រាជរដ្ឋាភិបាល រួមទាំងគម្រោង និងកម្មវិធី ដើម្បីអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំនិងមន្ត្រីជំនាញដែលដឹកនាំ គាំទ្រ និងចូលរួមអនុវត្តការងារកែទម្រង់ក្នុងក្រសួង ស្ថាប័ន។

៦- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ក.អ.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាលក្នុងក្រសួង ស្ថាប័ន។

៧- សម្របសម្រួលការងារប្រចាំថ្ងៃនិងបំពេញការងាររដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការអនុវត្តតួនាទីនិងភារកិច្ចរបស់ **គ.ក.អ.**។

៨- រៀបចំឯកសារ របាយការណ៍កិច្ចប្រជុំនិងសិក្ខាសាលានានាសម្រាប់ **គ.ក.អ.** ព្រមទាំងរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំនៃការអនុវត្តការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័ន ជូនប្រធាន **គ.ក.អ.**។

៩- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការសកម្មភាពនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាលក្នុងក្រសួង ស្ថាប័ន។

១០- រៀបចំចងក្រង និងផ្សព្វផ្សាយព័ត៌មានអំពីសមិទ្ធផលនានានៃការងារកែទម្រង់លើកកម្ពស់អភិបាលកិច្ចក្រសួង ស្ថាប័ន។

១១- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីប្រធាន **គ.ក.អ.**។

## ជំពូកទី៦
## ប្រភពធនធាន

**មាត្រា១៣ .-**

**គ.ក.អ.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នសាមី និងប្រភពធនធានស្របច្បាប់ផ្សេងទៀត។



96

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ២រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែ សីហា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ